ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. [illegible] MOC / SM 2006

# សេចក្តីជូនដំណឹង

# ស្តីពី

# ប្រការសំខាន់ៗនៃលក្ខន្តិកៈក្រុមហ៊ុន

អនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទិ ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ព្រមទាំងអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០០៥ ក្រសួងពាណិជ្ជកម្ម សូមប្រកាសជូនដំណឹងដល់អតិថិជនបានជ្រាបថា នៅពេលមកសុំចុះបញ្ជីពាណិជ្ជកម្មនៅការិយាល័យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ស្ថាបនិកឬអភិបាលក្រុមហ៊ុន ត្រូវយកលក្ខន្តិកៈចំនួន ០៣ ច្បាប់ ( បីច្បាប់ ) ដើម្បីធ្វើការតំកល់ទុកជាមួយសំណុំលិខិតសុំចុះបញ្ជីពាណិជ្ជកម្មផ្សេងទៀត។

**<u>លក្ខន្តិកៈក្រុមហ៊ុន ត្រូវមានចែងជាអាទិ៍ នូវចំណុចសំខាន់ដូចខាងក្រោម:</u>**

១-នាមករណ៏ក្រុមហ៊ុន

២-ទំរង់ក្រុមហ៊ុន

៣-កម្មវត្ថុអាជីវកម្មនិងសកម្មភាពចំបង

៤-ថិរវេលានៃសកម្មភាពក្រុមហ៊ុន

៥-ទីស្នាក់ការចុះបញ្ជី

៦-ដើមទុនជារូបិយវត្ថុជាតិ-ការបែងចែកជាភាគហ៊ុន-តំលៃចារឹកនៃភាគហ៊ុននិមួយៗ

៧-ឈ្មោះ មុខរបរ សញ្ជាតិ អាស័យដ្ឋាន អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែននៃម្ចាស់ហ៊ុនម្នាក់ៗ
 ចំណែកភាគហ៊ុនរបស់ម្ចាស់ហ៊ុនម្នាក់ៗ

៨-ឈ្មោះ សញ្ជាតិ អាស័យដ្ឋាន អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនព្រមទាំងអាណត្តិនៃអភិបាលម្នាក់ៗ

៩-ការទទួលនិងការបាត់បង់សមាជិកភាព

១០-គណនេយ្យ



Ministry of Commerce
20 A & B Preah Norodom Boulevard
Phnom Penh 12205
Kingdom of Cambodia

Senior Minister's Cabinet
Tel: (855) 23 427 358/214 946
Fax: (855) 23-213-288/991-708
E-mail: moccabdir@yahoo.com

១១-ការរំលាយ

១២-ការកែប្រែលក្ខន្តិកៈ

១៣-វិធីផ្សព្វផ្សាយជាសាធារណៈ

លក្ខន្តិកៈត្រូវរួមបញ្ចូលផងដែរ នូវរាល់ចំនុចផ្សេងៗទៀតតាមការចាំបាច់ ។

លក្ខន្តិកៈអាចធ្វើឡើងតាមរូបភាពជាលិខិតរវាងឯកជន ឬជាលិខិតសារការី ។ គ្រប់ទំព័រនៃលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវចុះហត្ថលេខាឬហត្ថលេខាសង្ខេប ដោយសមាជិកទាំងអស់របស់ក្រុមហ៊ុននោះ ។

សេចក្តីជូនដំណឹងនេះ ត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចំលងជូន</u>**

- មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង " ដើម្បីផ្សព្វផ្សាយ "
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce
20 A & B Preah Norodom Boulevard
Phnom Penh 12205
Kingdom of Cambodia

Senior Minister's Cabinet
Tel: (855) 23 427 358/214 946
Fax: (855) 23-213-288/991-708
E-mail: moccabdir@yahoo.com